ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មានស្តីពី
# លទ្ធផលកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ាន-អាមេរិក និងកិច្ចប្រជុំពាក់ព័ន្ធ
# ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ រដ្ឋធានីវ៉ាស៊ីងតោន សហរដ្ឋអាមេរិក

**********

ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ាន-អាមេរិក និងកិច្ចប្រជុំពាក់ព័ន្ធ នៅរដ្ឋធានីវ៉ាស៊ីងតោន នាថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧។ នេះគឺជាការជួបប្រជុំលើកទី១ រវាងរដ្ឋមន្ត្រីការបរទេសនៃប្រទេសសមាជិកអាស៊ាន និងឯកឧត្តម រ៉េច ធីល័រសុន រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក ចាប់តាំងពីរដ្ឋបាលថ្មីរបស់លោក ដូណាល់ ត្រាំ ចូលកាន់អំណាច នៅខែមករា ឆ្នាំ២០១៧។

កិច្ចប្រជុំបានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងរឹងមាំនៃការបន្តនិរន្តភាពនយោបាយរបស់លោកប្រធានាធិបតី ដូណាល់ ត្រាំ ចំពោះអាស៊ាន និងការផ្តល់ឱកាសជាថ្មីដើម្បីអនុវត្តគំនិតផ្តួចផ្តើមជាច្រើនដែលអាស៊ាន និងអាមេរិក បានឯកភាពគ្នា ជាច្រើនឆ្នាំកន្លងទៅ។

កិច្ចប្រជុំបានធ្វើការកត់សំគាល់សកម្មភាពរំលឹកខួបដែលបានគ្រោងទុក និងកំពុងប្រព្រឹត្តទៅដោយប្រទេសសមាជិកអាស៊ាន និងសហរដ្ឋអាមេរិកក្នុងការប្រារព្ធខួបលើកទី៤០នៃភាពជាដៃគូយុទ្ធសាស្ត្រ។

រដ្ឋមន្ត្រីការបរទេសអាស៊ាន បានស្វាគមន៍ចំពោះការប្រកាសថា ប្រធានាធិបតី ដូណាល់ ត្រាំ នឹងអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ាន-សហរដ្ឋអាមេរិក លើកទី៥ និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី ១២ ដែលនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកា ឆ្នាំ២០១៧ នៅប្រទេសហ្វីលីពីន ដែលនឹងអះអាងឡើងវិញពីការបន្តការប្តេជ្ញាចិត្តរបស់អាមេរិកចំពោះតំបន់ និងការធ្វើឲ្យស៊ីជម្រៅភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-អាមេរិក។ រដ្ឋមន្ត្រីការបរទេសអាស៊ានក៏បានសម្តែងអំណរសាទរចំពោះការគោរព និងការគាំទ្ររបស់អាមេរិក ចំពោះតួនាទីស្នូលរបស់អាស៊ាន និងរាល់យន្តការនានាដែលដឹកនាំដោយអាស៊ាន នៅក្នុងដំណើរវិវឌ្ឍនិម្មាបនកម្មនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។

កិច្ចប្រជុំមានការផ្លាស់ប្តូរទស្សនៈដោយស្មោះត្រង់ លើបញ្ហាតំបន់និងអន្តរជាតិដែលជាចំណាប់អារម្មណ៍រួម រួមមានការប្រឆាំងភេរវកម្ម ឧបទ្វីបកូរ៉េ និងសមុទ្រចិនខាងត្បូង។

ក្នុងអំឡុងពេលកិច្ចប្រជុំ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន បានគូសបញ្ជាក់ពីសារៈសំខាន់ និងភាពចាំបាច់ក្នុងការបន្តពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-អាមេរិក ដើម្បីជាគុណប្រយោជន៍ដល់សន្តិភាព សន្តិសុខ និងវិបុលភាពនៅក្នុងតំបន់។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

Scanned by CamScanner

Scanned by CamScanner